**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ : ០៩៧ សជណ

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០២

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ជំរាបជូន**

- **ឯកឧត្តម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន**
- **ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ក្រុងប៉ៃលិន ក្រុងកែប**
- **ឯកឧត្តម អភិបាលខេត្ត-ក្រុង**
- **លោកស្នងការនគរបាលខេត្ត-ក្រុង**

**កម្មវត្ថុ:** សេចក្តីជូនដំណឹងស្តីពីការអនុវត្តអនុក្រឹត្យលេខ ២៧ អ.ន.ក្រ បក ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០២ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ក្រសួងមហាផ្ទៃមានកិត្តិយស សូមជំរាបឯកឧត្តម លោកជំទាវ អស់លោក ទាំងអស់អោយបានជ្រាបថា : ដើម្បីឆ្លើយតបទៅនិងសំណូមពរ នៃភារកិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ក្នុងដំណាក់កាលបច្ចុប្បន្ន និងដើម្បីឱ្យសមស្របតួនាទីរបស់នគរបាលជាតិកម្ពុជាទៅនឹងបណ្តាប្រទេសនានានៅលើសកលលោក ថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ : ២៧ អ.ន.ក្រ បក ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបង្កើតអគ្គស្នងការដ្ឋាននគរបាលជាតិ ។

ខ្លឹមសារអនុក្រឹត្យចែងថា :

- ត្រូវបានកែសំរួលអគ្គនាយកដ្ឋាននគរបាលជាតិ មកជាអគ្គស្នងការដ្ឋាននគរបាល-ជាតិ ចំណុះក្រសួងមហាផ្ទៃ ។
- ត្រូវបានកែសំរួលអគ្គនាយកនគរបាលជាតិ មកជា អគ្គស្នងការនគរបាលជាតិ ។

ក្រសួងមហាផ្ទៃ នឹងចាប់អនុវត្តប្រើប្រាស់នៅក្នុងលិខិតបទដ្ឋាននានាជាផ្លូវការ ចាប់ពីថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០២ តទៅ ។

អាស្រ័យដូចបានជំរាបខាងលើ សូមឯកឧត្តម លោកជំទាវ អស់លោកជារដ្ឋមន្ត្រី រដ្ឋលេ-ខាធិការគ្រប់ក្រសួង ស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងស្នងការនគរបាលខេត្ត-

ក្រុងទាំងអស់មេត្តាជ្រាបជាពត៌មាន ។

សូមឯកឧត្តម លោកជំទាវ អស់លោកទាំងអស់ ទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

**សមរដ្ឋមន្ត្រី**

ស ខេង ឃឹម ឆាយលី

*ចំលងជូន*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ស្ថានទូតប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
- កាលប្បវត្តិ-ឯកសារ